**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ....០១...សរ......**

# សារាចរ

## ស្ដីពី

## ការត្រួតពិនិត្យ និង ការសំរបសំរួលក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈ

កន្លងមក រាជរដ្ឋាភិបាលបានពិនិត្យឃើញថា ការកសាងគំរោងកម្មវិធីវិនិយោគសាធារណៈ និងការរៀបចំគំរោងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចប្រាំឆ្នាំ បានជួបប្រទះការលំបាក និងមានការយឺតយ៉ាវបណ្ដាលមកពីការប្រមូលទិន្នន័យពីការអនុវត្តគំរោងមិនបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ប្រការនេះ ជាហេតុធ្វើឱ្យរាជរដ្ឋាភិបាល មានការពិបាកក្នុងការរៀបចំគោលនយោបាយ ដើម្បីអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ និងធ្វើឱ្យក្រុមប័ណ្ឌអ្នកផ្ដល់ជំនួយ និងកម្ចីពីបរទេស មានការលំបាកដោយសារពុំមានគំរោងជាក់លាក់ និងទិសដៅអភិវឌ្ឍន៍ប្រទេសច្បាស់លាស់ ។

ជាមួយគ្នានេះ ក្នុងការអនុវត្តគំរោងស្ដារបន្ទាន់ហេដ្ឋារចនាសម្ព័ន្ធខូចខាតដោយទឹកជំនន់ឆ្នាំ ២០០០ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និង បណ្ដាក្រសួងអនុវត្តគំរោង ព្រមទាំងភាគីផ្ដល់ឥណទានសហការគ្នាបានជិតស្និទ្ធល្អប្រសើរ ដែលញ៉ាំងអោយគំរោងទាំងឡាយអនុវត្តបានទាន់ពេល ហើយក្រសួងផែនការក៏មានលទ្ធភាពរាយការណ៍ជូនរាជរដ្ឋាភិបាល ពីសកម្មភាពអនុវត្តគំរោងបានតាមកាលកំណត់ ហើយក៏ត្រូវបានចាត់ទុកជាបទពិសោធន៍មួយមានប្រសិទ្ធភាពក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈដែរ ។

យោងតាមបទពិសោធន៍ខាងលើនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដូចតទៅ :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវពង្រឹងការអនុវត្តតាមស្មារតីអនុក្រឹត្យ លេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ អោយកាន់តែមានប្រសិទ្ធភាពថែមទៀត ។

២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និង បណ្ដាក្រសួង ស្ថាប័នទាំងអស់ ត្រូវបន្តសហការជិតស្និទ្ធជាមួយគ្នា ក្នុងការអនុវត្តគំរោងវិនិយោគសាធារណៈតាមបទពិសោធន៍ដ៏ល្អ ដែលសំរេចលទ្ធផល

ល្អប្រសើរ ក្នុងការអនុវត្តគំរោងស្តារបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធ ដែលបានរងការខូចខាតដោយទឹកជំនន់ នៅ ឆ្នាំ ២០០០ កន្លងមក។

៣- ប្រគល់ភារកិច្ចជូនក្រសួងផែនការ ធ្វើជាសេនាធិការផ្ទាល់អោយរាជរដ្ឋាភិបាល និងជាច្រកតែមួយគត់ ក្នុងការគ្រប់គ្រង តាមដាន និងសំរបសំរួលរាល់គំរោងវិនិយោគសាធារណៈ ដូចជា ការប្រើប្រាស់ ក្របខ័ណ្ឌជំនួយ និងកម្ចីពីបរទេស ក្នុងនោះរួមមាន ធនាគារ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ជំនួយឬកម្ចី ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល និងថវិការដ្ឋ ហើយត្រូវធ្វើរបាយការណ៍រួម ស្តីពីលទ្ធផល នៃការអនុវត្តគំរោងវិនិយោគសាធារណៈ ជូនរាជរដ្ឋាភិបាលតាមកាលកំណត់ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុង ត្រូវបង្កើនកិច្ចសហការអោយបានជិតស្និទ្ធ ជាមួយក្រសួងផែនការ ដើម្បីធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តតាមស្មារតី និងខ្លឹមសារដូចបានចែងខាងលើ អោយបានល្អត្រឹមត្រូវ និងទទួលបានលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ - កាលប្បវត្តិ